**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ១៧២០ ប្រក កសក

# ប្រកាស

## ស្តីពី

## ការគ្រប់គ្រងសកម្មភាពជីកកាស់ ជីកជញ្ជូន និង ធ្វើអាជីវកម្ម រុក្ខជាតិ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨ /១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការ រៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៨០១/៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០៥០៦/០១១ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៥ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងពូជដំណាំ និង សិទ្ធិអ្នកបង្កាត់ពូជ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
No. 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០
Phone (023) 726 128 / 726 129 Fax . (855) 23 217 320

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១៤៩ ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៥ ស្តីពីការកំណត់ប្រភេទសត្វ និង រុក្ខជាតិសម្រាប់ជានិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក.ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួល អគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និង កែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និង ការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការត្រួតពិនិត្យភូតគាមអនាម័យ
- បានឃើញអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៦ ស្តីពីការធ្វើពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និង រុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## សម្រេច

**ប្រការ ១ :**

ប្រកាសនេះមានគោលបំណងកំណត់នូវបទបញ្ញា ក្នុងការគ្រប់គ្រងសកម្មភាពជីកគាស់ ដឹកជញ្ជូន និង ធ្វើអាជីវកម្មគ្រប់រូបភាពនូវបណ្តាប្រភេទរុក្ខជាតិ ឬ ដើមឈើ ដែលមានអាយុកាលយូរលង់ ហើយមានសារសំខាន់ក្នុងប្រវត្តិសាស្ត្រ វប្បធម៌ ជំនឿសាសនា ប្រពៃណីជាតិ និង មានតម្លៃជាសម្បត្តិ ឬ មរតក ធម្មជាតិរួមរបស់ជាតិ ហៅកាត់ថា "រុក្ខជាតិ" ក្នុងគោលដៅចូលរួមថែរក្សា ការពារ និង អភិរក្ស ធនធានជីវចម្រុះរបស់ជាតិ។

**ប្រការ ២ :**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះ គ្រប់សកម្មភាពរបស់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលពាក់ព័ន្ធនឹងការជីកគាស់ ការដឹកជញ្ជូន ការធ្វើអាជីវកម្មគ្រប់រូបភាពនូវបណ្តាប្រភេទរុក្ខជាតិ ឬ ដើមឈើ ដូចមានចែងក្នុងប្រការ ១ នៃប្រកាសនេះ ក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រការ ៣ :

ការដឹកជញ្ជូន "រុក្ខជាតិ" ដែលមានអាយុកាលយូរលង់ និង មានទ្រង់ទ្រាយដើមទាំងស្រុង ដោយបានមកពីការជីកកាស់ចេញពីគ្រប់ទីតាំងនៃប្រភពដើម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានហាមឃាត់។

ប្រការ ៤ :

រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលមានបំណងជីកកាស់ "រុក្ខជាតិ" ដែលមានអាយុកាលយូរលង់ ដើម្បីដឹកជញ្ជូនយកមកធ្វើការដាំលម្អ ឬ បំប៉នដើម្បីដាំលម្អ ដែលមានទីតាំង និង គម្រោងជាក់លាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវស្នើសុំការអនុញ្ញាតជាមុនពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

ប្រការ ៥ :

ការធ្វើអាជីវកម្មគ្រប់រូបភាព ជាពិសេស ការនាំចេញ "រុក្ខជាតិ" ដែលមានអាយុកាលយូរលង់ និង មានទ្រង់ទ្រាយដើមទាំងស្រុង ដោយបានមកពីការជីកកាស់ចេញពីគ្រប់ទីតាំងនៃប្រភពដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានហាមឃាត់។

ប្រការ ៦ :

ការធ្វើអាជីវកម្មគ្រប់រូបភាព ឬ ការធ្វើសន្និធិនៅក្នុងសួន សម្រាប់លក់ចែកចាយនូវបណ្ដា "រុក្ខជាតិ" អាចប្រព្រឹត្តទៅបាន លុះត្រាតែ "រុក្ខជាតិ" ទាំងនោះបានមកពីការធ្វើពហុកម្ម ឬ ពង្រីកកូន ហើយត្រូវមានលិខិតអនុញ្ញាតធ្វើអាជីវកម្មចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

ប្រការ ៧ :

រាល់សកម្មភាពដឹកជញ្ជូន ឬ ធ្វើអាជីវកម្ម នូវពូជ "រុក្ខជាតិ" ដែលដាក់តាំងលក់ ឬ ធ្វើពហុកម្មសម្រាប់លក់ ត្រូវស្ថិតក្រោមការត្រួតពិនិត្យ និង អនុវត្តច្បាប់ ដោយមន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

ប្រការ ៨ :

រាល់សកម្មភាពជីកកាស់ ដឹកជញ្ជូន និង ធ្វើអាជីវកម្មគ្រប់រូបភាព នូវបណ្ដា "រុក្ខជាតិ" ទាំងឡាយដែលមានប្រភព ឬ ស្ថិតនៅក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ និង តំបន់គ្រប់គ្រងជលផល ត្រូវគ្រប់គ្រងដោយបទប្បញ្ញត្តិនៃច្បាប់ស្ដីពីព្រៃឈើ និង ច្បាប់ស្ដីពី ជលផលជាធរមាន។

៣

**ប្រការ ៩ :**

ជនណាដែលប្រព្រឹត្តល្មើសនឹងប្រកាសនេះ ត្រូវទទួលទណ្ឌកម្មតាមច្បាប់ជាធរមាន។

**ប្រការ ១០ :**

បទបញ្ជា ឬ សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១១ :**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម ប្រធានរដ្ឋបាលព្រៃឈើ ប្រធានរដ្ឋបាលជលផល ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធ ប្រធានមន្ទីរកសិកម្មរាជធានី ខេត្ត ត្រូវអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែមីនា ឆ្នាំ ២០១១

**រដ្ឋមន្ត្រី**

**ចាន់ សារុន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យលោកជំទាវឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលារាជធានី ខេត្ត
- ដូចប្រការ ១១
- ឯកសារ-កាលប្បវត្តិ

៤